# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 16-Aug-2013, 08:36
CMS/CFO: Phok Chanthan

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ សាធារណៈ/Public

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សំណើសុំឲ្យធ្វើការបំភ្លឺពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយសាក្សី ពាក្យបណ្តឹង និងប្រតិចារឹក និងការសុំពន្យារពេលវេលាផុតកំណត់សម្រាប់ការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល

---

**ដាក់ដោយ÷**

**ក្រុមសហមេធាវីការពារក្តីរបស់លោក នួន ជា:**

លោក សុន អរុណ

លោក Victor KOPPE

លោក ព្រំ ផល្លា

**ផ្ញើជូន ÷**

**សហចៅក្រមជាន់ចោទ**

**សហព្រះរាជអាជ្ញា:**

លោកស្រី ជា លាង

លោក Andrew CAYLEY

លោក សួន វិសាល

លោក Joshua ROSENSWEIG

លោកស្រី Forest ONEILL-GREENBERG

លោកស្រី Elizabeth BUDNITZ

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

លោក ពេជ អង្គ

លោកស្រី Elisabeth SIMONNEAU-FORT

សហមេធាវីការពារក្ដីលោក នួន ជា ("មេធាវីការពារក្ដី") សូមដាក់សំណើជាបន្ទាន់សុំឱ្យធ្វើការបំភ្លឺទៅលើស្ថានភាពនៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃកំណត់ហេតុស្ដាប់ចម្លើយសាក្សីដើម្បីយកមកធ្វើជាភស្ដុតាង និងការសុំពន្យារពេលវេលាផុតកំណត់សម្រាប់ការដាក់សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល។

## I. ប្រវត្តិនីតិវិធី

១. កាលពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យមានការបំភ្លឺពីអង្គជំនុំជម្រះសាលាដំបូងថា កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីទាំងអស់ អាចត្រូវបានទទួលយកធ្វើជាភស្ដុតាងបាន ឱ្យតែកំណត់ហេតុស្ដាប់នៃការស្ដាប់ចម្លើយសាក្សីទាំងនោះមានការពាក់ព័ន្ធ និងមានតម្លៃជាភស្ដុតាង[១]។ ក្រុមមេធាវីការពារក្ដីទាំងអស់បានបដិសេធ ដោយជំទាស់តវ៉ាថា អនុលោមតាមច្បាស់កម្ពុជា ភាសាច្បាស់លាស់នៃវិធានផ្ទៃក្នុង និងការធានាមុនៗរបស់សហចៅក្រមស៊ើបអង្កេតនោះកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីមិនអាចទទួលយកបានទេ ប្រសិនបើពុំមានឱកាសដើម្បីធ្វើការសួរតទល់នៅក្នុងសវនាការនោះទេ[២]។

២. មួយឆ្នាំក្រោយមក ហើយក៏ជារយៈពេលប្រាំបីខែក្រោយពីការចាប់ផ្ដើមសវនាការមក អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា វិធានស្ដីពីនីតិវិធីដែលបានបង្កើតនៅអន្តរជាតិទាក់ទងនឹងភាពអាចទទួលយកបាននៃកំណត់ស្ដាប់ចម្លើយហេតុសាក្សី អាចអនុវត្តចំពោះកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក បាន ("សេចក្ដីសម្រេចពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុនៃការស្ដាប់សម្លើយសាក្សី")[៣]។ នៅក្នុង

---

[១] ឯកសារ **E-96** "សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១។

[២] ជាឧទាហរណ៍ សូមមើលឯកសារ **E-96/1** "ចម្លើយតបទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងការទទួលយកកំណត់នៃហេតុស្ដាប់ចម្លើយសាក្សី" ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១១។

[៣] ឯកសារលេខ **E-96/7** "សេចក្ដីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី និងឯកសារនានា នៅចំពោះអង្គជំនុំជម្រះសាលាដំបូង" ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ ("សេចក្ដីសម្រេចពាក់ព័ន្ធនឹងការទទួលយកកំណត់នៃការហេតុស្ដាប់ចម្លើយសាក្សី")។

ចំណោមផ្នែកជាច្រើននៃរបបតតិយុត្តិរបស់អង្គជំនុំជម្រះសាលាដំបូង ភស្តុតាងនៃអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ មិនអាចទទួលយកបានទេ[៤]។ អង្គជំនុំជម្រះសាលាដំបូងបានណែនាំដល់សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណីឱ្យដាក់បញ្ជីដែលបានកែសម្រួលចម្លើយសាក្សី ដើម្បីឱ្យទទួលយកជាភស្តុតាង ដោយអនុលោមតាមលក្ខខណ្ឌទាំងនេះ។ អង្គជំនុំជម្រះសាលាដំបូងក៏បានណែនាំដល់ដើមបណ្ដឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា ឱ្យព្យាយាមកាត់បន្ថយចំនួនកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ដែលខ្លួនបានស្នើសុំឱ្យទទួលយកនេះ[៥]។

៣. កាលពីថ្ងៃទី ១៥ ខែ មិថុនា ថ្ងៃទី ៥ កក្កដា និងថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី បានដាក់ជូនបញ្ជីកែសម្រួល។ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ខ្លួនមិនអាចកាត់បន្ថយចំនួនកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ដែលខ្លួនបានស្នើឱ្យទទួលយកនោះបានទេ និងបានជំទាស់តវ៉ាថា កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីទាំងអស់នោះអាចទទួលយកបានទាំងស្រុង រួមទាំង ភស្តុតាងនៃអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទផងដែរ[៦]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំឱ្យទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៣.៨៦៦ ច្បាប់[៧]។

---

[៤] សេចក្ដីសម្រេចពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី។

[៥] សេចក្ដីសម្រេចពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ត្រង់កថាខណ្ឌ ៣៥(គ)។

[៦] ឯកសារលេខ **E-96/8** "សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា សុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នូវកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី និងប្រតិចារឹក ព្រមទាំងឧបសម្ព័ន្ធសម្ងាត់ពី ១ ដល់ ១៦" ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ ត្រង់កថាខណ្ឌ ១៧។ ឯកសារ **E-208** "សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យទទួលយកកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីពាក់ព័ន្ធនឹងការជម្លៀសប្រជាជននៅដំណាក់កាលទី ១" ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២។ ឯកសារ **E-208/2** "សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យទទួលយកកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពាក់ព័ន្ធនឹងការជម្លៀសប្រជាជននៅដំណាក់កាលទី ២ និងបញ្ជាភស្តុតាងផ្សេងទៀត ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ **I, II** និង **III** និងឧបសម្ព័ន្ធជាធារណៈ **IV**" ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១២។

[៧] ឯកសារលេខ **E-96/4.1** "ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ទៅនឹងសេចក្ដីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន ៩២ ស្ដួន ទាក់ទងនឹងការទទួលយកកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី និង

៤. នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន បានដាក់សំណើសុំឱ្យមានការបង្គាប់ដល់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ឱ្យកាត់បន្ថយចំនួនកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែលបានស្នើសុំឱ្យទទួលយកមកធ្វើជាភស្តុតាង។ ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន បានកត់សម្គាល់ឃើញឯកសារដែលត្រូវដោះស្រាយ និងការខកខានរបស់សហព្រះរាជអាជ្ញាក្នុងការកាត់បន្ថយចំនួនកំណត់ហេតុទាំងនេះ កំហុសជាច្រើនទៀតដែលត្រូវបានរកឃើញរួចមកហើយនៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដែលមាននៅក្នុងសំណុំរឿង និងភាពមិនស្របគ្នានៃកំណត់ហេតុទាំងនេះ ដោយឯកសារខ្លះមិនមានគ្រប់ភាសាផ្លូវការទាំងបីរបស់ អ.វ.ត.ក ឡើយ។ នៅក្នុងកាលៈទេសៈនេះ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា សិទ្ធិរបស់ លោក ខៀវ សំផន ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងឆាប់រហ័ស តម្រូវឱ្យសហព្រះរាជអាជ្ញាធ្វើការកែសម្រួលសំណើនាពេលបច្ចុប្បន្នរបស់ខ្លួន ដែលសុំឱ្យទទួលយកកំណត់ហេតុទាំងអស់នោះ [៨]។

៥. នៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធការជំទាស់របស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ទាក់ទងនឹងវិការៈក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការ និងបានកំណត់ពេលវេលាសម្រាប់ធ្វើការបកប្រែកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងពាក្យបណ្តឹងដែលនៅសេសសល់ទាំងអស់ទៅជាបីភាសា [៩]។ អង្គជំនុំជម្រះសាលាដំបូងមិនបានដោះស្រាយសំណើរបស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដែលស្នើសុំឱ្យបង្គាប់ដល់សហព្រះរាជអាជ្ញា និងដើមបណ្តឹង

---

ឯកសារដទៃទៀត នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង (ឯកសារលេខ **E-96/7** និងអនុស្សរណៈលេខ **E-208/3** រួមទាំងឧបសម្ព័ន្ធសម្ងាត់ ១ និង ២" ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ ត្រង់ **ERN 00842448-00842463**។

[៨] ឯកសារលេខ **E-223** "សារណាគាំទ្រលើសំណើរបស់លោក អៀង សារី ឯកសារលេខ **E221** និងស្នើសុំអង្គជំនុំជម្រះសាលាដំបូងឱ្យបង្គាប់ដល់សហព្រះរាជអាជ្ញាធ្វើការកែប្រែបញ្ជីស្តីពីកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលសហព្រះរាជអាជ្ញាមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់" ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២។

[៩] ឯកសារលេខ **E-223/2** "អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង" ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ ("អនុស្សរណៈចុះខែតុលា") ត្រង់កថាខណ្ឌ ៩។

រដ្ឋប្បវេណីឲ្យកាត់បន្ថយចំនួនកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែលត្រូវបានស្នើសុំឲ្យទទួលយកធ្វើជាភស្តុតាង និងការខកខានយ៉ាងពិតប្រាកដរបស់សហព្រះរាជអាជ្ញា ក្នុងការអនុវត្តឲ្យស្របតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ដល់ដើមបណ្តឹងរដ្ឋប្បវេណីឲ្យបញ្ជាក់បន្ថែមទៀតអំពីភាពជាប់ពាក់ព័ន្ធនៃកំណត់ហេតុស្តាប់ចម្លើយសាក្សីនានា ដែលខ្លួនបានបន្តស្នើសុំឲ្យទទួលយក និងបង្គាប់ឲ្យដាក់ជូនអង្គជំនុំជម្រះសាលាដំបូង នូវបញ្ជីមួយដែលបានធ្វើការកែសម្រួល នៅត្រឹមថ្ងៃទី ៤ ខែ មីនា ឆ្នាំ២០១៣។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថាក្រុមមេធាវីការពារក្តីគួរតែដាក់ការជំទាស់ នៅត្រឹមថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣[១០]។

៦. នៅថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ ក្រុមមេធាវីការពារក្តី នួន ជា បានដាក់ចម្លើយតបជាបឋមទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពាក្យបណ្តឹង និងប្រតិចារឹកទៅធ្វើជាភស្តុតាង។ ក្រុមមេធាវីការពារក្តីបានជំទាស់តវ៉ា នៅក្នុងចំណោម*បញ្ហាជាច្រើន* ថា៖ (i) បទដ្ឋានដែលកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងសេចក្តីសម្រេចពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុនៃការស្តាប់សម្លើយសាក្សីនេះ មិនស្របទៅនឹងវិធានស្តីពីនីតិវិធី ដែលបានបង្កើតនៅកម្រិតអន្តរជាតិ ដែលបានយកមកសំអាងនៅក្នុងសេចក្តីសម្រេចនោះទេ (ii) តម្រូវឲ្យមានការបញ្ជាក់បន្ថែមទៀតទាក់ទងនឹងចំណុចជាក់លាក់មួយចំនួននៃលក្ខខណ្ឌដែលបានកំណត់នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង រួមទាំងទាក់ទងទៅនឹងនិយមន័យនៃឃ្លាថា "អំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ" និងការទទួលយកកំណត់ហេតុដែលមិនមានការកោសលុប ដែលមានភស្តុតាងដែលមិនអាចទួលយកបាន ហើយ (iii) ចំនួនកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដែលបានស្នើសុំដោយសហព្រះរាជអាជ្ញា ឲ្យទទួលយកមកធ្វើជាភស្តុតាងនោះ ច្រើនពេកដែលមិនចាំបាច់ច្រើនដូច្នេះ និងការងាកចេញយ៉ាងខ្លាំងពីការអនុវត្តជាក់ស្តែងដែលកំពុងអនុវត្តនៅកម្រិតអន្តរជាតិ[១១]។ អាស្រ័យហេតុនេះ មេធាវីការពារក្តីបានស្នើសុំឲ្យមានការបំភ្លឺទាក់ទងទៅនឹងបទដ្ឋានគតិយុត្តិដែលអាច

---

[១០] អនុស្សរណៈចុះខែ តុលា ចាប់ពីកថាខណ្ឌ ១២ ដល់ ១៤។

[១១] ឯកសារលេខ **E-96/8/1** "ការឆ្លើយតបជាបឋមទៅនឹងសំណើបន្ថែមរបស់សហព្រះរាជអាជ្ញា សុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារឹក" ចុះថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១២។

យកមកអនុវត្តបាន និងសេចក្តីសម្រេចបឋមទាក់ទងទៅនឹងប្រទេភឯកសារដែលបានជ្រើសរើស។

៧. បន្ទាប់ពីនោះភ្លាម សហព្រះរាជអាជ្ញាបានសុំការអនុញ្ញាតដើម្បីឆ្លើយតបទៅនឹងសារណាទាំងអស់របស់ក្រុមមេធាវីការពារក្តី ដែលពាក់ព័ន្ធនឹងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នៅក្នុងចម្លើយតបរួមតែមួយ នៅពេលណាមួយក្រោយពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣[១២]។ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតតាមការស្នើសុំនោះ ប៉ុន្តែបានបដិសេធសំណូមពរដែលស្នើសុំដោយក្រុមមេធាវីការពារក្តីលោក នួន ជា នៅមុនកាលបរិច្ឆេទកំណត់[១៣]។

៨. នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានប្រកាន់យកជំហររបស់ខ្លួនដែលថា សហព្រះរាជអាជ្ញាមិនបានប្រមើលឃើញជាមុនថា ខ្លួនអាចកាត់បន្ថយចំនួនកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី "ដ៏ច្រើនលើសលុប" ដែលបានស្នើសុំឲ្យទទួលយកនោះបានទេ[១៤]។ នៅថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ការកាត់បន្ថយដែលអាចធ្វើទៅបាននោះ នឹងអាចដាក់ជូននៅត្រឹមថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣ "ដូច្នេះ ទុករយៈពេលជាងពីរខែឲ្យភាគីដទៃទៀតពិចារណាលើការជំទាស់បន្ថែមទៀត"[១៥]។ នៅថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាបានផ្លាស់ប្តូរជំហរពីមុនរបស់ខ្លួន និងបានបញ្ជាក់ថា "យើងខ្ញុំអាចកាត់បន្ថយពីបញ្ជីដើមចំនួន ៥០% និងអាចកាត់បន្ថយច្រើនជាងនេះទៅទៀតបាន។ និយាយរួម ការកាត់បន្ថយនេះនឹងជួយសម្រាលយ៉ាងខ្លាំងដល់កិច្ចការដ៏ច្រើន ដើម្បីឲ្យភាគីទាំងអស់ពិនិត្យឡើងវិញនូវកំណត់ហេតុទាំងនេះ និងរៀបចំធ្វើការជំទាស់ណាមួយទៅតាមនោះ"[១៦]។ សហព្រះរាជអាជ្ញា ក៏បានកែប្រែកាលបរិច្ឆេទដែលខ្លួនបានប្រមើល

---

[១២] អ៊ីមែលពីលោក **William Smith** ផ្ញើជូនភាគីទាំងអស់ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១២។

[១៣] អ៊ីមែលពីលោកស្រី **Susan Lamb** ផ្ញើជូនភាគីទាំងអស់ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១២។

[១៤] អ៊ីមែលពីលោក **William Smith** ផ្ញើជូនភាគីទាំងអស់ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១២។

[១៥] អ៊ីមែលពីលោក **William Smith** ផ្ញើជូនភាគីទាំងអស់ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២។

[១៦] អ៊ីមែលពីលោក **William Smith** ផ្ញើជូនភាគីទាំងអស់ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៣។

សម្រាប់ការដាក់បញ្ជីដែលបានកាត់បន្ថយរបស់ខ្លួន ទៅដល់ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៣។

៩. នៅថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូលបានធ្វើមោឃភាពទៅលើសេចក្តីសម្រេចពីមុនរបស់អង្គជំនុំជម្រះសាលាដំបូង ដែលសម្រេចបំបែកដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយមិនបង្កការប៉ះពាល់ទៅដល់លទ្ធភាពនៃការបំបែកកិច្ចដំណើរការនីតិវិធីជាថ្មី នៅក្រោមកាលៈទេសៈជាក់លាក់ណាមួយនោះឡើយ[១៧]។ នៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាបានសុំការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូងដើម្បីដាក់បញ្ជីចុងក្រោយបំផុតរបស់ខ្លួននៃកំណត់ហេតុស្តាប់ចម្លើយសាក្សី រយៈពេលពីរសប្តាហ៍ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចចុងក្រោយរបស់ខ្លួនទាក់ទងនឹងវិសាលភាពនៃការជំនុំជម្រះ។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធ និងបានបង្គាប់ឲ្យសហព្រះរាជអាជ្ញាចាប់ដំណើរការទៅតាមពេលវេលាដែលបានកំណត់[១៨]។ នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ការជូនដំណឹងជាមុនអំពីគោលបំណងរបស់ខ្លួនក្នុងការបំបែកដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងតម្កល់សំណុំរឿង ០០២/០១ ដូចដែលមានស្រាប់មុនការចេញសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល[១៩]។ ដប់ពីរថ្ងៃក្រោយមក គឺនៅថ្ងៃទី ៩ ខែ មេសា ២០១៣ សហព្រះរាជអាជ្ញាបានដាក់បញ្ជីដែលបានកែសម្រួលនៃកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលកាត់បន្ថយកំណត់ហេតុមកនៅត្រឹម ១.០៥០ ច្បាប់ ដែលត្រូវស្នើសុំឲ្យយកជាធ្វើជាភស្តុតាង។ សហព្រះរាជអាជ្ញាក៏បានផ្លាស់ប្តូរជំហរពីមុនរបស់ខ្លួនដែលថា ភស្តុតាងនៃអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទអាចទទួលយកបាន។ អាស្រ័យហេតុនេះ វាជាលើកដំបូងហើយដែលសហព្រះរាជអាជ្ញាបានបង្កលទ្ធភាពដល់ភាគីទាំងអស់ចំពោះការកាត់បន្ថយកំណត់ហេតុដែល

---

[១៧] ឯកសារលេខ **E-163/5/1/13** "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០១" ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[១៨] ការឆ្លើយឆ្លងអ៊ីមែលរវាងលោក William Smith និងលោកស្រី Susan Lamb នៅថ្ងៃទី ១៤-១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[១៩] ឯកសារលេខ **E-1/206.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី" ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣។

បានស្នើសុំ ចំនួន ២២០ ច្បាប់ពីចំនួនកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទាំង ១.០៥០ ច្បាប់[២០]។

១០. នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន និងលោក នួន ជា បានដាក់ការជំទាស់ជាចុងក្រោយរបស់ខ្លួន ស្របតាមតារាងកំណត់ពេលវេលារបស់អង្គជំនុំជម្រះសាលាដំបូង។ ដោយបានទទួលបញ្ជីកាត់បន្ថយរបស់សហព្រះរាជអាជ្ញា ១៦ ថ្ងៃជាមុន មេធាវីការពារក្តីបានជំទាស់ថា ខ្លួនមិនបានទទួលការជូនដំណឹងជាមុនឲ្យបានគ្រប់គ្រាន់ សម្រាប់ការពិភាក្សាដេញដោលទាក់ទងទៅនឹងការកាត់បន្ថយទាំងនោះ និងថា ការកាត់បន្ថយទាំងនោះគួរត្រូវបានអង្គជំនុំជម្រះសាលាដំបូងច្រានចោល ហើយថា កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទាំងនោះ គួរតែត្រូវបានដកចេញពីភស្តុតាង[២១]។

១១. នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា សេចក្តីសម្រេចទាក់ទងទៅនឹងភាពអាចទទួលយកបាននៃកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពាក្យបណ្តឹង និងប្រតិចារឹក នឹងត្រូវចេញនៅក្នុងអំឡុងពីពីរទៅបីសប្តាហ៍ទៀត ហើយថា "កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួនប្រហែល ១.៥០០ ច្បាប់ នឹងត្រូវបានធ្វើចំណាត់ថ្នាក់ **E3** ក្នុងពេលឆាប់នេះ នៅពេលដែលសេចក្តីសម្រេច និងឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ ត្រូវបានបញ្ចប់រួចរាល់"[២២]។

១២. នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៣ មេធាវីការពារក្តីបានផ្តល់ច្បាប់ចម្លងនៃសំណើសុំស្តាប់សក្ខីកម្ម

---

[២០] ឯកសារលេខ **E-278** "សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអំពីឧបសម្ព័ន្ធទី ១២ និងទី ១៣ ដែលបានកែសម្រួលឡើងវិញ ក្នុងបញ្ជីឯកសាររបស់ខ្លួនសម្រាប់សវនាការ អនុលោមតាមវិធាន ៨០(៣) (កំណត់ហេតុស្តាប់ចម្លើយសាក្សី និងបណ្តឹង)" ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៣។

[២១] ឯកសារលេខ **E-223/2/8**៖ "ការជំទាស់ទៅនឹងសំណើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារឹក" ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៣ ពីកថាខណ្ឌ ១៧ ដល់ ១៩ ពីកថាខណ្ឌ ៣១ ដល់ ៣៣ និងកថាខណ្ឌ ៤៣។ ឯកសារលេខ **E-223/2/8/1**៖ "ឧបសម្ព័ន្ធបន្ថែមពាក់ព័ន្ធនឹងការជំទាស់ទៅនឹងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារឹក" ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣។

[២២] ឯកសារលេខ **E-1/207.1**៖ "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី" ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ២៦:១១-១២។

សាក្សីថ្មីៗទៀត ដោយផ្អែកទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួន ១.៥០០ ច្បាប់មកធ្វើជាភស្តុតាង។ មេធាវីការពារក្តីបានជំទាស់ថា កំណត់ហេតុទាំងនេះទំនងជាដាក់បញ្ចូលចម្លើយជាច្រើន ឬទាំងអស់ ដែលបានដកស្រង់ដោយសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា ក្នុងការគាំទ្រដល់ការចោទប្រកាន់របស់ខ្លួនដែលថា គោលនយោបាយសម្លាប់ទាហាន និងមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ មានអត្ថិភាពនៅក្នុងខែមេសា ឆ្នាំ ១៩៧៥[២៣]។ មេធាវីការពារក្តីបានជំទាស់ថា ខ្លួនមានសិទ្ធិសួរដេញដោលសាក្សីទាំងនេះដោយសារតែសក្ខីកម្មនេះមានសារៈសំខាន់ដែលអាចត្រូវបានដាក់បញ្ចូលនៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទាំងនេះ។ មេធាវីការពារក្តីបានជំទាស់បន្ថែមទៀតថា ដោយសារតែការសួរតទល់តម្រូវឱ្យធ្វើឡើងតែក្នុងករណីដែលចម្លើយសាក្សីទាំងនេះទំនងជាអាចត្រូវបានទទួលយក ដូច្នេះ សំណើរបស់ខ្លួនត្រូវបានដាក់ជូនឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ហើយការដាក់សំណើនេះទាន់ពេលវេលាកំណត់។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើសុំនោះ នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ដោយសារការមិនមានការយកចិត្តទុកដាក់ឱ្យបានគ្រប់គ្រាន់[២៤]។

## II. ឧទ្ធរណ៍

១៣. តាមពិតទៅ ទាំងក្រុមមេធាវីការពារក្តីលោក នួន ជា និងក្រុមមេធាវីការពារក្តីលោក ខៀវ សំផន នៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនោះ បានខិតខំអនុវត្តន៍យ៉ាងយកចិត្តទុកដាក់មុនពេលផុតកំណត់កាលបរិច្ឆេទរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការស្នើសុំឱ្យមានការចេញសេចក្តីសម្រេចទាក់ទងនឹងការទទួលយកសក្ខីកម្មរបស់សាក្សីរាប់ពាន់ទំព័រដែលមិនទាន់បានសួរដេញដោល ដែលភាគីបានស្នើសុំឱ្យយកមកធ្វើជាភស្តុតាង។ នៅដើមខែ កក្កដា ឆ្នាំ ២០១១ ក្រុមមេធាវីការពារក្តីបានតវ៉ាថា ប្រសិនបើការទទួលយកចម្លើយសាក្សីត្រូវបានសម្រេច ដោយអនុលោមតាមវិធាននានារបស់តុលាការ *មិនអចិន្ត្រៃយ៍* នោះតម្រូវឱ្យមានការវាយតម្លៃទៅលើកំណត់ហេតុនីមួយៗ ម្តងមួយៗ មុននឹង

---

[២៣] ឯកសារលេខ **E-291/2**៖ “សំណើសុំឱ្យកោះហៅសាក្សីពាក់ព័ន្ធនឹងការចោទប្រកាន់អំពីគោលនយោបាយនៃការកំណត់មុខសញ្ញាមន្ត្រីសាធារណរដ្ឋខ្មែរ” ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៣។

[២៤] ឯកសារលេខ **E-1/227.1**៖ “ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី” ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៦៧:២២-៦៨:៧។

ទទួលយកកំណត់ហេតុនោះបាន[២៥]។ នៅខែ វិច្ឆិកា ឆ្នាំ ២០១២ ក្រុមមេធាវីការពារក្តីលោក នួន ជា បានលើកឡើងពីការជំទាស់តវ៉ានេះជាលម្អិត[២៦]។

១៤. ក្រោយពីការពន្យារពេលអស់ពីរឆ្នាំ ដោយមិនមែនបណ្តាលមកពីជនជាប់ចោទណាម្នាក់ឡើយ ក្រុមមេធាវីការពារក្តីត្រូវបានផ្តល់ពេលវេលាតែ ១៦ ថ្ងៃ ដើម្បីរៀបចំការជំទាស់របស់ខ្លួន គិតពីពេលដែលសហព្រះរាជអាជ្ញាបានដាក់សំណើចុងក្រោយរបស់ខ្លួន សុំឱ្យទទួលយកកំណត់ហេតុទាំងនោះ។ សហព្រះរាជអាជ្ញាបានធ្វើមិនដឹងមិនឮចំពោះសេចក្តីណែនាំដោយផ្ទាល់ពីអង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងកិច្ចដំណើរការនោះយ៉ាងហោចណាស់ពីរដងក្នុងអំឡុងពេលនោះដែរ[២៧]។ អង្គជំនុំជម្រះសាលាដំបូងហាក់ដូចជាយល់ព្រមទៅនឹងទង្វើបែបនោះ ដោយបានសម្រេចទទួលយកកំណត់ហេតុរបស់សហព្រះរាជអាជ្ញាទាំងអស់ ឬស្ទើរតែទាំងអស់។ ហេតុដូច្នេះ នៅក្នុងកាលៈទេសៈទាំងនេះ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបានរំលោភសិទ្ធិរបស់ជនជាប់ចោទក្នុងការសួរដេញដោល និងតទល់នឹងភស្តុតាងដែលដាក់បន្ទុកលើរូបគាត់រួចទៅហើយ។ អង្គជំនុំជម្រះសាលាដំបូងបានធ្វើឱ្យការរំលោភនោះកាន់តែធ្ងន់ធ្ងរទៀត ដោយបានពន្យារការសម្រេចសេចក្តីទៅលើភាពអាចទទួលយកចម្លើយទាំងនោះរហូតមកដល់កាលបរិច្ឆេទដែលយឺតពេលទៅហើយនេះ ហើយបន្ទាប់មកបានផ្អែកទៅលើភាពយឺតយ៉ាវនោះ បដិសេធសំណើរបស់មេធាវីការពារក្តី ដែលសុំធ្វើការជំទាស់តវ៉ាចំពោះចម្លើយសាក្សីដែលត្រូវបានទទួលយកនាពេលថ្មីៗនេះ នៅក្នុងសវនាការសាធារណៈ[២៨]។

១៥. ដោយការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលជិតមកដល់ ហើយមិនមានការចេញ

[២៥] ឯកសារលេខ **E-96/3**៖ “ចម្លើយតបរបស់លោក អៀង សារី ចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី នៅចំពោះអង្គជំនុំជម្រះសាលាដំបូង និងសំណើសុំឱ្យបើកសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ” ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ពីកថាខណ្ឌ ២២ ដល់ ២៧។

[២៦] *សូមមើល* កថាខណ្ឌ ៨ *ខាងលើ*។

[២៧] *សូមមើល* កថាខណ្ឌ ៣ និងកថាខណ្ឌ ៩ *ខាងលើ*។

[២៨] *សូមមើល* កថាខណ្ឌ ១២ *ខាងលើ*។

សេចក្តីសម្រេចនៅឡើយនោះ នាពេលនេះកំពុងតែមានការបន្តរំលោភសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការការពារខ្លួន។ ទោះបីជាគេអាចសន្មតបានថា នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ពីចេតនារបស់ខ្លួនក្នុងការទទួលយកកំណត់ហេតុភាគច្រើនលើសលុបទៅធ្វើជាភស្តុតាងក៏ដោយ ក៏នៅតែមានភាពមិនច្បាស់លាស់ជាច្រើនក្នុងពេលបច្ចុប្បន្ន ហើយនឹងបន្តប៉ះពាល់ដល់លទ្ធភាពរបស់លោក នួន ជា ក្នុងការរៀបចំសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់គាត់ដដែល។ ជាពិសេស មេធាវីការពារក្តីមិនទាន់បានទទួល៖

ក. សេចក្តីសម្រេចចុងក្រោយរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងបទដ្ឋានទូទៅដែលត្រូវយកមកអនុវត្តក្នុងការសម្រេចពីវិសាលភាពនៃ "អំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ" ឬការវាយតម្លៃមួយបន្ទាត់ម្តងៗរបស់ខ្លួនទៅលើភស្តុតាង ដែលអាចមាននៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែលសហព្រះរាជអាជ្ញាបានស្នើសុំឱ្យទទួលយកធ្វើជាភស្តុតាង។

ខ. សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះសេចក្តីសម្រេចថ្មីៗរបស់ខ្លួនក្នុងការទទួលយកកំណត់ហេតុទាំងអស់ (ឬស្ទើរតែទាំងអស់) ដែលដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឱ្យទទួលយកទៅធ្វើជាភស្តុតាង ដោយមិនគិតពីកំហុសរបស់ពួកគេក្នុងការកោសលុបភស្តុតាងទាក់ទងនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ឬការវាយតម្លៃមួយបន្ទាត់ម្តងៗរបស់ខ្លួនទៅលើភស្តុតាងបែបនោះ ដែលអាចមាននៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីនីមួយៗ។

គ. ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងការជំទាស់ទៅនឹងឯកសារមួយចំនួនតូច ដូចជា កំណត់ហេតុចម្លើយដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា[២៩] ឬកំណត់ហេតុទាំង

[២៩] ឯកសារ **E-223/2/8**៖ "ការជំទាស់ទៅនឹងសំណើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារឹក" ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ពីកថាខណ្ឌ ៤៥ ដល់ ៤៦។

ឡាយទាក់ទងនឹងទួលពោធិ៍ជ្រៃ[៣០] ដែលនៅតែមិនអាចទទួលយកបានដោយអង្គជំនុំជម្រះសាលាដំបូងនៅឡើយ បើទោះជាមានការបញ្ជាក់កាលពីថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ នោះឬ

ឃ. ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងការជំទាស់ទៅនឹងឯកសារនីមួយៗដែលនៅតែមិនអាចទទួលយកបានដោយអង្គជំនុំជម្រះសាលាដំបូង បើទោះជាមានការបញ្ជាក់កាលពីថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ នោះក្តី។

១៦. ពេលវេលាដែលត្រូវការសម្រាប់ពិនិត្យទៅលើសេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះសាលាដំបូងបានធ្វើឱ្យមេធាវី នួន ជា វល់វយៈពេលជាច្រើនសប្តាហ៍។ តាមកាលវិភាគនាបច្ចុប្បន្ន ក្រុមមេធាវីការពារក្តីលោក នួន ជា បានប្រឹងប្រែងយ៉ាងខ្លាំង និងកំពុងតែធ្វើការអស់ពីសមត្ថភាព។ នៅដំណាក់កាលនេះ ភារកិច្ចពិនិត្យមើលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង អាចប៉ះពាល់យ៉ាងខ្លាំងដល់លទ្ធភាពរបស់លោក នួន ជា ក្នុងការរៀបចំការការពារខ្លួន និងកាន់តែធ្វើឱ្យការរំលោភសិទ្ធិដែលមានរួចទៅហើយ ក្នុងការស្នើរតទល់ទៅលើភស្តុតាងដាក់បន្ទុកទៅលើរូបគាត់ កាន់តែមានភាពធ្ងន់ធ្ងរឡើង។

១៧. ដោយយោងទៅលើសំអាងហេតុទាំងនេះ មេធាវីការពារក្តីសូមសំណូមពរដោយក្តីគោរពដល់អង្គជំនុំជម្រះសាលាដំបូងមេត្តា៖

ក. ផ្តល់ក្របខ័ណ្ឌពេលវេលាឱ្យបានច្បាស់លាស់ជាបន្ទាន់សម្រាប់ការចេញសេចក្តីសម្រេចមួយទាក់ទងនឹងការជំទាស់ទាំងអស់របស់មេធាវីការពារក្តី ប្រឆាំងទៅនឹងការទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពាក្យបណ្តឹង និងប្រតិចារឹក។

ខ. ចេញសេចក្តីសម្រេចដែលបានលើកឡើងនេះជាបន្ទាន់ រួមទាំងឧបសម្ព័ន្ធជាលម្អិតមួយដែលមានបញ្ជីឯកសារដែលបានទទួលយកទាំងអស់ ដោយមានសំអាងហេតុដាច់ដោយឡែក

[៣០] ឯកសារ **E-291**៖ "សំណើបន្ទាន់សុំឱ្យកោះហៅសាក្សីសំខាន់ៗទាក់ទងនឹងទួលពោធិ៍ជ្រៃ" ចុះថ្ងៃទី ១៧ ខែ មិថុ ឆ្នាំ ២០១៣ ពីកថាខណ្ឌ ៣៤ ដល់ ៣៩។

សម្រាប់ឯកសារនីមួយៗ ដែលឯកសារទាំងនេះមានការជំទាស់តវ៉ាជាក់លាក់ដែលបានប្ដឹង និងភ្ជាប់នូវអត្ថបទដែលបានកោសលុបនៃឯកសារនីមួយ ដើម្បីដាក់បញ្ចូលជាភស្តុតាងស្ដីពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដោយមានការបង្ហាញពីភាពជាក់លាក់នៃផ្នែកដែលអាចទទួលយកបាន និង

គ. ប្រកាសថា សវនាការសួរដេញដោលទៅលើភស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ ត្រូវបានបញ្ចប់ដោយមិនឱ្យមុនកាលបរិច្ឆេទចេញសេចក្ដីសម្រេចដែលបានលើកឡើងនោះទេ និងកំណត់កាលបរិច្ឆេទផុតកំណត់សម្រាប់ការដាក់សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ភាគី មិនឱ្យឃឹតជាងប្រាំមួយសប្ដាហ៍ គិតចាប់ពីកាលបរិច្ឆេទនោះមកទេ។

**សហមេធាវីការពារក្ដីលោក នួន ជា**

សុន អរុណ Victor KOPPE